ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា
## បម្រើការងារនៅនាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

នាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាផ្នែកព័ត៌មានវិទ្យាចំនួន ១០ រូប ដើម្បីបម្រើការងារនៅក្នុងនាយកដ្ឋានព័ត៌មានវិទ្យា ដែលមានជំនាញ និង លក្ខខណ្ឌដូចខាងក្រោម ៖

- មន្ត្រីជំនាញផ្នែកផលិតកម្មវិធីលើទូរស័ព្ទដែលមានប្រព័ន្ធដំណើរការ Android (Android App Programmer) ចំនួន ០១ រូប
  - មានជំនាញក្នុងការសរសេរកូដភាសា Java, C# (Good in Java and C# Programming)
  - មានចំណេះដឹងច្បាស់លាស់ផ្នែក Object-Oriented Programming
  - មានចំណេះដឹងក្នុងការប្រើប្រាស់ Android SDK
  - ធ្លាប់មានបទពិសោធន៍ផលិតកម្មវិធីលើទូរស័ព្ទប្រភេទ Android ( សូមភ្ជាប់ជាឯកសារយោង) ។
- មន្ត្រីជំនាញផ្នែកផលិតកម្មវិធីលើទូរស័ព្ទដែលមានប្រព័ន្ធដំណើរការ iOS (iOS App Programmer) ចំនួន ០១ រូប
  - មានជំនាញក្នុងការសរសេរកូដភាសា Objective-C (Good in Objective-C)
  - មានចំណេះដឹងច្បាស់លាស់ផ្នែក Object-Oriented Programming
  - មានចំណេះដឹងក្នុងការប្រើប្រាស់ iOS SDK
  - ធ្លាប់មានបទពិសោធន៍ផលិតកម្មវិធីលើទូរស័ព្ទប្រភេទ iOS ( សូមភ្ជាប់ជាឯកសារយោង) ។
- មន្ត្រីជំនាញផ្នែកសរសេរកម្មវិធីកុំព្យូទ័រ (Programmer) ចំនួន ០៣ រូប
  - មានជំនាញក្នុងការសរសេរកូដភាសា .Net Programming (C#, Visual Basic) ឬ Java ឬ ASP.Net ឬ PHP Programming
  - មានចំណេះដឹងច្បាស់លាស់ផ្នែក Object-Oriented Programming
  - មានចំណេះដឹងផ្នែក Database Management System
  - ធ្លាប់មានបទពិសោធន៍បង្កើតកម្មវិធីកុំព្យូទ័រមួយចំនួនដែលដំណើរការលើប្រព័ន្ធដំណើរការ Windows ឬ Web-based ( សូមភ្ជាប់ជាឯកសារយោង) ។

➤ មន្ត្រីជំនាញផ្នែករៀបរៀង ឬ រចនាគេហទំព័រ (Web Designer) ចំនួន ០១ រូប

- មានចំណេះដឹងក្នុងការសរសេរកូដភាសា HTML, CSS, JavaScript ឬ VBScript និង XML
- មានគំនិតច្នៃប្រឌិតខ្ពស់លើផ្នែករចនាគេហទំព័រ (Web Template Design)
- ធ្លាប់មានបទពិសោធន៍រចនា និង បង្កើតគេហទំព័រមួយចំនួន (សូមភ្ជាប់ជាឯកសារយោង) ។

➤ មន្ត្រីជំនាញផ្នែកគ្រប់គ្រងគេហទំព័រ និង សារអេឡិចត្រូនិក (Web Master) ចំនួន ០១ រូប

- មានចំណេះដឹងក្នុងការគ្រប់គ្រង និង ថែទាំ Hosting Server ដូចជា ការប្រើប្រាស់ CPanel, WHM, Name Server, Spacing Quota, Monitor Web Traffic, Backup&Restore ។ល។
- មានចំណេះដឹងក្នុងការគ្រប់គ្រង និង ថែទាំ Mail Server ដូចជា ការគ្រប់គ្រង Spam Filter និង បង្កើតគណនីថ្មីជាដើម ។

➤ មន្ត្រីជំនាញផ្នែកជួសជុល និង ថែទាំម៉ាស៊ីនកុំព្យូទ័រទាំងផ្នែក Hardware និង Software ចំនួន ០២ រូប

- មានចំណេះដឹងទូទៅផ្នែក Hardware និង Software ពាក់ព័ន្ធនឹងម៉ាស៊ីនកុំព្យូទ័រ
- ធ្លាប់មានបទពិសោធន៍ជួសជុល ថែទាំ និង ដំឡើង Hardware និង Software ម៉ាស៊ីនកុំព្យូទ័រ (សូមភ្ជាប់ជាឯកសារយោង)
- ធ្លាប់មានបទពិសោធន៍ដោះស្រាយបញ្ហា (Trouble Shooting) លើការប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័រ ។

➤ មន្ត្រីជំនាញផ្នែកបណ្តាញតភ្ជាប់ (Networking) ចំនួន ០១ រូប

- មានចំណេះដឹងខាងផ្នែកតភ្ជាប់បណ្តាញ ដូចជាការធ្វើ Configuration ប្រព័ន្ធ Netowrk និង Cabling ជាដើម
- ធ្លាប់មានបទពិសោធន៍អនុវត្តផ្ទាល់ក្នុងការតភ្ជាប់ និង ដំឡើងបណ្តាញតភ្ជាប់ (សូមភ្ជាប់ឯកសារយោង) ។

**<u>លក្ខខណ្ឌជ្រើសរើសរួម</u>**

១. ត្រូវមានសញ្ញាបត្របរិញ្ញាបត្រពត៌មានវិទ្យា ឬ វិទ្យាសាស្ត្រកុំព្យូទ័រឡើងទៅ

២. ត្រូវមានចំណេះដឹងភាសាអង់គ្លេសសមរម្យ

៣. ត្រូវមានឆន្ទៈ និង មនសិកាក្នុងការបំពេញការងារជូនស្ថាប័នរដ្ឋ និង មានសីលធម៌ក្នុងការរស់នៅល្អ

៤. ត្រូវមានការព្យាយាម និង តស៊ូបំពេញការងារក្រោមលក្ខខណ្ឌពិបាក និង មានអត្តចរិតស្លូតបូត ស្លូតត្រង់ និង ម៉ឺងម៉ាត់

៥. បេក្ខជនគឺជាជនជាតិខ្មែរ មានសញ្ជាតខ្មែរ និង មានអាយុមិនលើសពី ៣០ ឆ្នាំ ។

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប និង ឯកសារពាក់ព័ន្ធមកនាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានអាសយដ្ឋានផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ អាគារ “ខ” ជាន់ទី៦ ឬផ្ញើតាមរយៈអ៊ីមែល itd.info@mef.gov.kh ឱ្យបានមុនថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦។

*រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ មីនា ឆ្នាំ ២០១៦*

ទំនាក់ទំនងលេខទូរស័ព្ទ ÷ ០១២ ៦២៩ ៩៥៦